# *សិលាចារឹកសំស្ក្រឹតនៅសំបូរព្រៃគុក K.440 (ភាគ ១)*

*បើយោងទៅតាមការសិក្សារបស់ប្រវត្តិវិទូដ៏ល្បីល្បាញ គឺលោក **ម៉ៃឃើល វីឃើរី** បានបញ្ជាក់ថា យ៉ាងហោចណាស់មានសិលាចារឹកចំនួន ៧ រកឃើញនៅតំបន់ប្រាសាទសំបូរព្រៃគុកដែលរៀបរាប់អំពីព្រះបាទឦសានវរ្ម័នទី១។ ក្នុងនោះ យើងសង្កេតឃើញថា មានតែសិលាចារឹកនៅក្រុមប្រាសាទយាយព័ន្ធប៉ុណ្ណោះដែលបានរំលេចច្រើនអំពីការពោលសរសើរព្រះអង្គ ហើយជាពិសេសសិលាចារឹកដែលចារនៅលើមេទ្វារកំពែងខាងកើតនៃក្រុមប្រាសាទយាយព័ន្ធ K.440 គឺមានព័ត៌មានអំពីព្រះមហាក្សត្រអង្គនេះច្រើនជាងគេបំផុត។ នៅក្នុងអត្ថបទនេះ យើងនឹងបង្ហាញអំពីអត្ថន័យ និងខ្លឹមសារទាំងស្រុងអំពីសិលាចារឹកនេះ ប៉ុន្តែនៅក្នុងភាគទី១ យើងនឹងបង្ហាញតែអក្សរចារឹកនៅមេទ្វារខាងត្បូងមួយចំហៀងសិនប៉ុណ្ណោះ ហើយមួយចំហៀងទៀតនៅលើមេទ្វារខាងជើងនឹងបង្ហាញនៅភាគទី២។ តើសិលាចារឹកដែលរកឃើញនៅមេទ្វារខាងត្បូងកំពែងខាងកើតនៃក្រុមប្រាសាទយាយព័ន្ធមានអត្ថន័យយ៉ាងណាខ្លះ?*

*សំណេរនៅលើមេទ្វារកំពែងខាងកើតនៃក្រុមប្រាសាទយាយព័ន្ធ គឺផ្ដើមសាច់រឿងពីមេទ្វារខាងត្បូងមក។ សិលាចារឹកនេះ សរសេរជាកំណាព្យសំស្ក្រឹតតាមបែបអនុស្ដុភ ដែលមានស្លោកសរុបចំនួន ១៧ ហើយធ្លាប់សិក្សាដោយលោក ហ្សក សឺដេស ម្ដងរួចមកហើយ។ យើងឃើញថា ចារឹកនេះមិនបានបញ្ជាក់ឈ្មោះអ្នកនិពន្ធទេ ពោល គឺមានត្រឹមបញ្ជាក់អំពីព្រះនាមព្រះបាទឦសានវរ្ម័នទី១ ដែលអត្ថន័យជាទូទៅរៀបរាប់យ៉ាងជាក់ច្បាស់អំពីបុគ្គលិកលក្ខណៈ ការគ្រប់គ្រង និងដឹកនាំប្រទេស និងរូបសម្បត្តិរបស់ទ្រង់។ តាមខ្លឹមសារនេះ ហាក់ដូចជាព្រះបាទឦសានវរ្ម័នទី១ មានរូបសម្បត្តិស្រស់សង្ហាណាស់ ព្រមទាំងមានចំណេះដឹង និងគុណធម៌ដ៏វិសេសវិសាលទៀតផង។ ក្នុងរាជ្យរបស់ទ្រង់ ទំនងជាតំបន់មួយចំនួនបានញាំញីដោយសឹកសង្គ្រាមផង ទើបបានជាកំណាព្យនេះមានរៀបរាប់ពីវីរភាពរបស់ទ្រង់ក្នុងសមរភូមិ។*

*មុននឹងប្រែខ្លឹមសារទាំងស្រុងនៃសិលាចារឹកនេះ ខ្ញុំសូមសម្រាយដោយសង្ខេបអំពីស្លោកនីមួយៗជាមុនសិន។ ក្នុងនោះស្លោកទី១ រៀបរាប់ពីព្រះឦគ្វរ (ឥសូរ) ក្រោមរូបភាពជាលិង្គមាននាមថា ស្រីប្រហសិតេស្វរ ដែលមានន័យថាសំណើចព្រះឥសូរ ឬព្រះឥសូរទ្រង់ញញឹម។ ព្រះស្រីប្រហសិតេស្វរ ជាឧត្តមសិវលិង្គ ដែលជាប្រធានក្នុងក្រុមប្រាសាទយាយព័ន្ធ ឬហៅថាក្រុមខាងត្បូងនេះ ហើយលិង្គនេះតម្កល់នូវត្រង់ប្រាង្គកណ្ដាលនៃប្រាសាទយាយព័ន្ធ។ នៅក្នុងស្លោកនេះថែមទាំងបានលែងវោហារសព្ទថា ព្រះស្រីប្រហសិតេស្វរ មានពន្លឺរស្មីចែងចាំង ដែលប្រដូចទៅ*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

នឹងផែនប្រឹថពី ក្នុងសមុទ្រពណ៌មាស។ ស្លោកទី២ ពោលសរសើរគុណធម៌របស់ព្រះបាទស្រីសានវម៌្មទី១ ដោយប្រើវោហារសព្ទពីរោះដូចជា គ្រីមតាមិ អវនីទ្រ្វាណាមិ អន្វយាម្វរ ភាស្វតះ (ព្រះអង្គប្រដូចដួងព្រះសូរិយាកំពុងបញ្ចេញរស្មីចិញ្ចែងចិញ្ចាចលើអាកាសា ទ្រង់ជាព្រះញាតិវង្សរបស់ព្រះមហាក្សត្រ ដែលមានជ័យមង្គល)។ ក្នុងអត្ថបទសិលាចារឹកបានប្រដូចអំណាចរបស់ទ្រង់ទៅនឹងកំដៅរបស់ព្រះសូរិយា ពោលគឺនៅពេលទ្រង់ស្ថិតនៅចំកណ្តាលមណ្ឌល ទ្រង់មានកំដៅ ឬអំណាចដែលមិនអាចមានជនណាម្នាក់មកប្រដូចបានឡើយ។

ស្លោកទី៣ ពោលសរសើរសេរីរៈគុណលក្ខណៈសម្រស់របស់ព្រះបាទគ្រីគានវម៌្មទី១ ថាមានសម្រស់ល្អគន់ឥតបីគណនា បើនរណាបានឃើញ ឬគយគន់ហើយរមែងពេញដោយហោចទៅសូម្បីតែព្រះនាងរតិដែលជាទេវីរបស់ព្រះកាមទេពក៏ភ្ញាត់ព្រះឱស្ឋពោលថា ខ្លួនដូចទៅនិងស្រីមេម៉ាយអញ្ចឹងដែរ។ ស្លោកទី៤ រៀបរាប់ថាទ្រង់ពេញព្រះរាជហឫទ័យចំពោះតែចំណេះវិទ្យា បើទោះជាទ្រង់កំពុងស្ថិតនៅក្នុងយុវវ័យក៏ដោយ ហើយនារីក្រមុំទាំងឡាយរមែងមិនហ៊ានចោមរោមទ្រង់នោះទេ បើទោះបីទ្រង់មានព្រះរូបឆោមលោមពណ៌គួរជាទីប្រាថ្នាក៏ដោយ។ ស្លោកទី៥ មានការលុបអស់អត្ថន័យជាច្រើន ដូច្នេះអត្ថន័យមិនពេញលេញឡើយ។ ស្លោកទី៦ ពណ៌នាអំពីសិរីយសរបស់ព្រះមហាក្សត្រ ដែលប្រដាប់ដោយរត្នវត្ថុទាំងឡាយ ប្រដូចទៅនឹងមហាសមុទ្រដែលអនុបាលដោយភ្នំ។ ស្លោកទី៧ រៀបរាប់ថាព្រះអង្គប្រសើរពេកក្រៃ មិនមាននរណាអាចប្រដូច ឬស្មើបាន ដោយហោចសូម្បីតែស្ត្រីជនទាំងឡាយ ទ្រព្យសម្បត្តិទាំងឡាយក៏មិនប្រសើរដូចឡើយ។

ស្លោកទី៨ រៀបរាប់ថាគុណលក្ខណៈរបស់ទ្រង់រឹងមាំក្រៃលែង ដែលទទួលបានការស្រោចស្រពដោយមន្ត្រ។ ស្លោកទី៩ រៀបរាប់ថាព្រះអង្គ គឺជាព្រះមហាក្សត្រប្រកបដោយសុចរិត ជាមហាក្សត្រមានចិត្តកតញ្ញូភក្តិចំពោះគ្រូបាធ្យាយ បើទោះបីទ្រង់មានកំណើតជាក្សត្រ និងមានយសធំក៏ដោយ ហើយទ្រង់អាចនឹងពង្រីកដែនវិស័យបន្ថែម។ ស្លោកទី១០ រៀបរាប់ថាសាធុសប្បុរសទាំងឡាយពោលសរសើរព្រះអង្គថា ទ្រង់ជាក្សត្រដែលតែងផ្តល់ទីជ្រកកោនអាស្រ័យដល់ជនទាំងពួង ព្រះអង្គស្អប់ខ្ពើមអំពើបាប (ទោស) ហើយព្រះអង្គបានលើកតម្កើងភាពត្រឹមត្រូវដោយប្រកាសយកអំពើអាក្រក់ធ្វើជាសត្រូវទី១របស់ព្រះអង្គ។ ស្លោកទី១១ ពណ៌នាអំពីគុណលក្ខណៈសម្បត្តិរូបឆោមលោមពណ៌ព្រះបាទស្រីសានវម៌្មទី១ដោយពាក្យថា ព្រះស្រីវរអង្គ (រូបរាង្គកាយដ៏ល្អប្រសើរស្រស់ស្អាត) ដោយការពោលសរសើរទ្រង់ច្រើនដង បង្ហាញឱ្យដឹងថា ព្រះបាទស្រីសានវម៌្មទី១ទំនងជា

អត្ថបទដោយ៖ កំ វណ្ណារ៉ា

*មានរូបសម្បត្តិស្រស់សង្ហាណាស់។ ស្លោកទី១២ ដល់ទី១៧ រៀបរាប់អំពីលក្ខណៈសម្បត្តិ សិរីយសភាពអស្ចារ្យ និងគោលនយោបាយទាំងបីរបស់ទ្រង់ក្នុងការដឹកនាំប្រទេស។*

## អត្ថបទចារឹកដើម

### *មេទ្វារខាងត្បូង*

| | | |
|---|---|---|
| ១. | .........រ ជយតិ | ស ត្រីប្រហសិ[តេក្វរះ] |
| | យស្យាង្គ[ ភាសា មត្នេរ] | ទ្រុតហេមាម្ពុជៅ មហី។ |
| ២. | ត្រីមតាមរដីទ្រ្វាណា | មង្វយាម្វភាស្វតះ |
| | មណ្ឌលេមឌ្យមស្យាបិ | ប្រតាចោ យស្យ ទុស្សហះ។ |
| ៣. | យំ កាន្តវបុមំ ធ្មម្វា | វិស្មិតេវាភវទ្រតិះ |
| | អហោ នុ មិថ្យា វៃជវ្យ | វញ្ចិតាស្មិ ចិរាជិតិ។ |
| ៤. | ត្រីតរុណ្យាបរិម្វក្តះ | កាម្យ្រូចោ យុវាបិយះ |
| | កុក្តាសុ វ្ម្ទៃវ្វីឡាសុ | វក្តxបរិណតាម្វបិ។ |
| ៥. | ស្វយំ.................... | .........មយិតាបិយះ |
| | ភក្តវត្បល.....យុ...... | ............ស្វរិភិះ។ |
| ៦. | វត្នេរុទន្វានិវ យx | បរិបូណ្ណ៌ោប្យនុន្ទតិះ |
| | ចាតា.........បក្សានិ | ទ្រ្វាឧបិ មហីភ្ឫតាំ។ |
| ៧. | បរេអាំ វិត្តជារេមុ | យស្យ ណិភោ និរាស្បុះ |
| | ស្វិត+គោវលមាចារ | សុក្ឫតា..តកីត្តឹមុ។ |
| ៨. | ធ្ឫឈម្វលា ទុរាពេហា | ពហុតា ខាx បពេហិណះ |
| | មន្ត្រាម្ពុសិក្តា វលិធា | យស្យ ជយមហីរុហា។ |
| ៩. | ប្រថមោ ភូតិ សុវ្ឫត្តាជាំ | កុរុកក្តិមតាញ្ច យះ |
| | គក្ត្យា វិមយមយ៌្យាទាំ | កុរុណាំ លង្ឃ្យយន្នបិ។ |
| ១០. | ន សភ្វ៌ត្រយ ឥត្យុក្ត | ស្បជ្ជនៃរិយតៃវ យះ |
| | ធោមៃយ៌្យជវិសម្បត្តិ៌ | ឧប៌្យាជិវ ន សេវិតះ។ |
| ១១. | យំ មនោហារិលាវន្យ | មិក្សមាណា វរាង្គនាះ |
| | និមេបមបិ នេត្រាណា | មវិក្ឫហ្យមម្បុត។ |

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

១២. មហីយោ យស្យ និស្សំខ្យ  មុបលក្យាំមលំ យតះ
ជាតាបិ ន ជគត ស្វម្ត  មល្យមិត្យមនុគោចតិ។
១៣. យស្យាភិយានេ វជសា  វលោមច្ឆ៌កុវា កុវះ
វរណាមិ សត្វភេទានាំ  អាវិម្ភូតតមំ តម។
១៤. យស្យ គក្តិត្រយវតា  ឥយេន បរក្វុក្មតះ
ក្វូតា វសជ្ជា× ចាតស្យ  វូឈម្វូលាះ ក្សីតាវបិ។
១៥. ស្វាថៅបសវង្គៃនោ ភូត្វា  បរាត៌្មិ មុខ្យវត្តិតះ
យ× ប្រណោតាភវងិ ទ្រវ្យេ  គុណាគព្ធ ឥវោជិតះ។
១៦. បូជ្វាជីនាំ ក្រុតា គក្តិរ  អគ្រេច្ឆេយាបិ សាំប្រតៃះ
ជីតា សំភាវ្យតាំ យស្យ  ធ្ម្វា សំយតិ វិក្រមមិ។
១៧. ប្រត្យហំ ភូបតិភិខា  វត្ស្យតិការាង្គ៌ុភិះ
ជីតៅ តរលតាំ យស្យ  ចរណាវមលាវបិ។

**បំណកប្រែ**

***មេឡារខាងត្បូង***

*១. ព្រះស្រីប្រហសិតេស្វរអង្គនោះ រមែងមានជ័យជម្នះ...ព្រះរូបរាង្គកាយរបស់ព្រះស្រីប្រហសិតេស្វរអង្គនោះទ្រង់មានពន្លឺភ្លឺចែងចាំង ដូច្នេះឯងទើបពោលថា ផែនដី នៅក្នុងសមុទ្រមាស (ពណ៌ក្រហមដូចមាស)។*

*២. ស្ដេចផែនដីអង្គនោះ ព្រះអង្គមានព្រះកិត្តិសព្ទល្បីល្បាញ ព្រះអង្គជាប់ព្រះញាតិវង្សខាងសូរ្យវង្ស ព្រះអង្គប្រដូចទៅនឹងដួងព្រះអាទិត្យនៅលើអាកាសវេហា ដោយហោចទៅសូម្បីតែព្រះអង្គគង់នៅក្នុងកណ្ដាលមណ្ឌល (រាជមន្ទីរ) ក៏ដោយ ក៏ព្រះអង្គទ្រង់មានកំដៅ (អំណាច)មិនមានបុគ្គលណាអាចទប់ទល់បានឡើយ។*

*៣. នរណាដែលបានគយគន់ឃើញហើយនូវព្រះវររូបកាយ ដែលមានរូបឆោមលោមពណ៌ល្អស្រស់ឆើតឆាយ ដោយហោចទៅសូម្បីតែនាងរតិ ក៏បានភ្ញាក់ដឹងខ្លួន ហើយបានពោលពាក្យដូច្នេះថា ឱហ្ន៎ ស្មានអញជាស្ត្រីមេម៉ាយយូរហើយទេតើ តែវាដូចជាមិនពិតនោះទេ។*

*៤. ស្រីតរុណ្យកញ្ញា (ស្រីក្រមុំព្រហ្មចារីយ៍) រមែងមិនហ៊ានចោមរោមជុំជិតព្រះអង្គនោះទេ បើទោះបីជាព្រះអង្គកំពុងនៅវ័យកំលោះ មានកាមរូប (ល្អស្រស់ឆើតឆាយ) ក៏ដោយ ដោយសារ*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

តែព្រះអង្គពេញចិត្តតែចំណោះវិជ្ជាមួយមុខប៉ុណ្ណោះ ដោយព្រឹទ្ធាចារ្យទាំងឡាយបានបរិភោគ (អាស្រ័យហើយ) រីករាយពេញចិត្ត។

៥. ស្វយំ =ខ្លួនឯង ..................បិយះ=សេចក្ដីពេញចិត្ត ......ភក្តវត៍=មានសេចក្ដីគោរព..សូរិកិះ=ដោយព្រះអាទិត្យទាំងឡាយ។

៦. ព្រះរាជាអង្គណា ទ្រង់បរិបូណ៌ដោយរត្នសម្បត្តិទាំងឡាយច្រើនប្រការ ដូចទៅនឹងមហាសមុទ្រ បាតា=ការពារដោយស្ដេចភ្នំ។

៧. ព្រះអង្គមិនមានបុគ្គលណាប្រៀបប្រដូចបាន ភាពដែលមាននៅក្នុងស្ត្រី ឬទ្រព្យសម្បត្តិដ៏ល្អប្រសើរទាំងអស់ស្ថិតនៅក្បែរព្រះអង្គបាន ត្បិតថាព្រះអង្គទ្រង់ប្រព្រឹត្តតែអំពើល្អដ៏សុក្រឹត...ក្នុងកិត្តិគុណប៉ុណ្ណោះ។

៨. ព្រះអង្គ (ព្រះបាទស្រីសានវរ្ម័ទី១) មានមូល (ឫសគល់) ដ៏រឹងមាំក្រៃលែង មានបែកមែកសាខា មានដុះត្រួយពន្លកច្រើន ដោយបានការស្រោចស្រពដោយទឹកមន្ត្រ មានផ្លែផ្កាច្រើន នេះជាដើមជ័យព្រឹក្សរីកលូតលាស់ដុះដាលលើផែនដីទ្រង់។

៩. ស្ថិតនៅក្នុងចំណោមបុគ្គលដែលប្រព្រឹត្តអំពើសុចរឹតទាំងឡាយ បុគ្គលអ្នកគោរពនិងដឹងគុណចំពោះគ្រូបាធ្យាយ ព្រះអង្គ (ព្រះបាទស្រីសានវរ្ម័ទី១) ជាបុគ្គលទី១ មានប្រក្រតីប្រព្រឹត្តសុចរឹត មានភក្ដីភាពចំពោះគ្រូបាធ្យាយ ទោះបីទ្រង់មានអំណាចធំក៏ពិតមែនក៏ដោយ។ ព្រះអង្គបានពង្រីកដែនវិស័យរបស់ទ្រង់ឱ្យធំទូលាយជាងគ្រូទាំងឡាយរបស់ទ្រង់ទៅទៀត។

១០. សាធុសប្បុរសជនទាំងឡាយដ៏ច្រើន ពោលសរសើរទ្រង់ថា ព្រះអង្គ (ព្រះបាទស្រីសានវរ្ម័ទី១) មិនត្រឹមតែជាទីជ្រកអាស្រ័យបណ្ដាជនប៉ុណ្ណោះទេ ព្រះអង្គមិនប្រព្រឹត្តដោយនូវទោសទាំងឡាយ ដោយទ្រង់ប្រដូចនូវការសេពគប់នូវទោស (អំពើបាប) នេះថាជាសត្រូវរបស់ទ្រង់។

១១. វរ-អង្គនា = រូបរាង្គកាយទាំងឡាយដ៏ល្អប្រសើររបស់ទ្រង់ កាលមើលនូវរូបល្អសោភានៃព្រះអង្គដែលមានរូបស្រស់ស្អាត នឹកក្នុងចិត្តថាគ្រាន់តែក្រលែកមើលមួយប៉ព្រិចភ្នែក ដូចជាចាប់បានសត្រូវទៅហើយ។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

១២. ព្រះសិរីយសដ៏ល្អបរិសុទ្ធឥតមន្ទិលសៅហ្មងដ៏ធំ មានច្រើនអនេករាប់មិនអស់ ព្រះធាតា (ទេពបង្កើតលោក) ទ្រង់មានព្រះតម្រិះតូចចិត្តថា ផែនដីដែលទ្រង់គ្រប់គ្រងនេះតូចពេកណាស់។

១៣. អភិយានេ រជសា= នៅពេលចូលទៅក្បែរព្រះរាជា ធូលីដីហុយទ្រលោមមកលើផែនដី ដែលបង្កើតឡើងដោយកងទ័ពរបស់ទ្រង់ បង្កើតបានជាភាពងងឹតខ្មួលខ្មាញ់ បានបង្ហាញអំពីភាពខុសប្លែកគ្នារវាងសត្វ។

១៤. គោលនយោបាយរបស់ព្រះអង្គ (ព្រះបាទស្រីសានវរ្ម័ទី១) បានបង្កើតឡើងដោយគោលការណ៍៣យ៉ាង នៃអំណាចរបស់ព្រះអង្គ បានធ្វើឱ្យព្រះរាជាក្រៅដែនអាណាចក្រ(បរទេស) ពេញចិត្ត (សាទរជាមួយគោលនយោបាយ) និងដួលរលំអំណាច បើទោះបីជាគេមានឫសគល់រឹងមាំនៅក្នុងដែនដីរបស់គេក៏ដោយ។

១៥. ព្រះអង្គទ្រង់ព្រះតម្រិះនូវអត្ថប្រយោជន៍ ដោយការប្រព្រឹត្តដ៏ឧត្តមរបស់ទ្រង់ ដោយព្រះអង្គបានបង្កើតប្រយោជន៍ដល់អ្នកដទៃ ដូចជាការបង្ហាញនូវគុណធម៌។

១៦. អំណាចដែលបានកំណត់ថាជាឫថុជាដើម និងជនដទៃ វាមានលក្ខណៈ អស្ចារ្យណាស់ ទោះបីជាវាមិនគួរឱ្យជឿក៏ដោយ តែបានបង្ហាញឱ្យគេឃើញយ៉ាងច្បាស់ អំពី តម្លៃក្នុងពេលប្រយុទ្ធ។

១៧. ជាប្រក្រតី ពន្លឺភ្លើងបានភ្លឺផ្លេកបែងចាំងភ្លឺឡើង ជាគ្រឿងរណ្ដាប់ដោយវត្ថុលម្អរប្រដាប់នៅលើព្រះក្ដួងសិរសាចុះមកក្រោមរបស់ព្រះមហាក្សត្រ បានភ្លឺជះចែងចាំងរស្មីភ្លឺត្រចះត្រចង់ មានពណ៌ល្អចម្រុះពណ៌ជះទៅលើព្រះបាទាទាំងគូដែលល្អបរិសុទ្ធឥតសៅហ្មង។

ជារួមមក សិលាចារឹកនេះ អាចចាត់ទុកថា គឺជាសិលាចារឹកដែលចារឹកល្អបំផុតរកឃើញក្នុងតំបន់ប្រាសាទសំបូរព្រៃគុក ដោយអ្នកនិពន្ធពូកែក្នុងការប្រើប្រាស់ពាក្យពេចន៍ ណែងណងល្អិតល្អន់ពីរោះរណ្ដំ តាមបែបសញ្ញាលង្ការពិធី និងអឋាលង្ការពិធី។ សិលាចារឹកនេះ បានផ្ដល់នូវព័ត៌មានជាច្រើនទាក់ទងនឹងបុគ្គលិកលក្ខណៈសម្បត្តិ និងរបៀបរបបគ្រប់គ្រងប្រទេសរបស់ព្រះបាទឦសានវរ្ម័នទី១៕

អត្ថបទដោយ៖ កំ វណ្ណារ៉ា

# ឯកសារយោង

**Coedès, George**
1954, *Inscription du Cambodge*, Vol VI, Hanoi.
**Vickery, Michael**
2000 - 2001, *Summary of lectures given at the Faculty of Archaeology, Royal University of Fine Arts*, Phnom Penh.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION



រូបលេខ១៖ ប្រាសាទយាយព័ន្ធ ប្រាង្គកណ្ដាល (រូបថត៖ លួន ទីយា)



រូបលេខ២៖ ការផ្ដិតសិលាចារឹកមេទ្វារខាងត្បូង នៃកំពែងខាងកើត ក្រុមប្រាសាទយាយព័ន្ធ K.440

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៣៖ សំណៅផ្ដិតសិលាចារឹកមេទ្វារខាងត្បូង នៃកំពែងខាងកើត ក្រុមប្រាសាទយាយព័ន្ធ K.440
(ផ្ដិតដោយ៖ កំ វណ្ណារ៉ា និង ម៉ង់ រ៉ាលី)

អត្ថបទដោយ៖ កំ វណ្ណារ៉ា